ការចង់ដឹងអំពី អនាគត

យោងតាម ការសរសេរ និង ការនិយាយ តាមតែចិត្ត រាល់ថ្ងៃ របស់ខ្លួន ស្តីអំពី ព្រឹត្តិការណ៍ ថ្មីៗ នៃជីវិតរស់នៅ, មនុស្សលោក ភាគច្រើន មិនសូវមានការចង់ដឹង អំពី ពុទ្ធិ (connaissance) ពិតប្រាកដ នៃបច្ចុប្បន្នកាល ហើយក៏ មិនសូវ ចាប់អារម្មណ៍ លើ អតីតកាលដែរ ដែល នាំចិត្តចង់ស្វែងធ្វើ នូវប្រវត្តិវិទ្យា តិចជាង រីាទ នៃមនោវិជ្ជា។ តែ ការចង់ដឹកអំពី អនាគត វិញ មនុស្សលោក យល់ឃើញថាវាផ្តល់ នូវគ្រប់អត្ថប្រយោជន៏ ហើយ នាំគ្នា ធ្វើការសិក្សា អំពីអ្វីមួយគ្មានសោះ ដែលជា ការស្រមៃ មិននៅក្រោមការត្រួតត្រា នៃការពិត សំរាប់ឆ្លើយបដិសេធ បានភ្លាម, ពុំនោះ ការស្រមៃនោះ រាបង្ហូន លាយ ក្នុងអនាគត ដ៏សន្ធឹងមួយ។ នុះ ដែលជាហេតុ ដែលនាំ១ មនុស្សលោកមាន ការចាប់អារម្មណ៍លើ អនាគត។ ជាឧទាហរណ៏ ក្រោយពីសង្គ្រាម លោកលើកទី២ គេឃើញមានបង្កើត ជាច្រើន នូវ វិជ្ជាដ្ឋាន នៃ ការិយបរិច្ឆេទ, អបរកាលវិជ្ជា (futurologie), ទស្សនវិស័យ។ តាំងពីពេលនោះមក រដ្ឋាភិបាល និង សហគ្រាសធំៗ ទាំងឡាយ នៅលើពិភពលោក តែងតែ រស្វេយក សេចក្តីរាយការណ៏ ស្តីអំពី ចក្ខុវិស័យអនាគតអ្វីមួយ របស់វិជ្ជាដ្ឋាននោះ ជាភ្លើងបំភ្លឺ ក្នុង ការសម្រេចធ្វើអ្វីមួយ ដើម្បីស្វែងរក នូវប្រសិទ្ធភាព នៃជម្រើស (optimiser le choix) របស់ខ្លួន។

ពីបុព្វេ នៅស្រុកខ្មែរ ក៏មានដែរ អបរកាលវិជ្ជា។ ហើយខ្មែរ ភាគច្រើន មានជំនឿណាស់លើ រាសនា ដូច្នេះ មុននឹងធ្វើអ្វីមួយ ត្រូវ រក ហោរ ព្យាករ តាមក្បួនតារាសាស្ត្រ ជាមុនសិន ដើម្បី ជៀសនឹងជួបប្រទះ នូវរាសនាអាក្រក់ ឬ ជ្រើសរក ថ្ងៃមានឫក្ស ដើម្បីធ្វើអោយបានជោគជ័យ នៃកំរោងរបស់ខ្លួន។ បើតាម ពុទ្ធទំនាយ ស្តីអំពី និស្ស័យ នៃប្រជាជនខ្មែរ តទៅអនាគត បានចារថា :

« *សម័យថ្ងៃមួយ, ព្រះសម្ពន:គោតម ព្រះពុទ្ធបរមគ្រូ បានយាងត្រេចរ ទៅគ្រប់ទិសទីកន្លែង ដោយមាន ព្រះអនន្ទជា សារ: ដង្ហែរអមព្រះដំណើរ ដើម្បីប្រោសអស់សព្វសត្វលោក។ ព្រះអង្គ បានយាងទៅដល់កោះជម្ពូទ្វីប កាត់តាមផ្ទៃមហាសាគរ មកដល់ទីកន្លែងមួយ មានដើម ផ្ទក ដុះបែកមែក សាខាត្រសុំត្រសាយ។ នៅក្រោមដើមផ្ទកនោះ មានរូងមួយយ៉ាងជ្រៅ ដែលជារូង របស់ស្តេច ភុជង្គនាគ សំរាប់ចេញចូល មកក្រសាលលេង។ នៅលើដើមផ្ទក មានសត្វត្រកួត មួយក្បាល រស់នៅដោយសុខសាន្ត។ នៅពេលថ្ងៃលិច ព្រះពុទ្ធអង្គ និង ព្រះអនន្ទ ក៏នាំគ្នានិមន្ត ចូលសំរាកក្រោមដើមផ្ទក។ ព្រឹកព្រហាមស្រាងកាលណា ព្រះអង្គ ចាប់ផ្តើមស្ទឹងស្ទាធ ប្រមើលមើលនិស្ស័យ អស់គ្រប់សត្វជិតឆ្ងាយ ដែលព្រះអង្គត្រូវនិមន្តទៅប្រោស។ បន្ទាប់មក ទ្រង់សោយចង្ហាន់។ ដោយធំក្លឹនម្ហូបអាហារ ឈ្ងុយឆ្ងាញ់ពេក សត្វត្រកួត ក៏ចុះពីដើមឈើ។ ព្រះអង្គឃើញ ទ្រង់ក៏ពូតបាយ ហើយ បោះទៅអោយសត្វនោះ ទុកធ្វើជាអាហារ។ ឆ្ងាញ់ពេក ត្រ*

ក្ងួត លិតមាត់លិតក លានអណ្ដាតចេញមកក្រៅ។ ទតឃើញក្រ ក្ងួត មានអណ្ដាតព្រែក បែកចេញជាពីរ ព្រះពុទ្ធ ទ្រង់ឈ្ងោក ព្រះភ័ក្ត្រ សម្លឹងទៅព្រះធរណី ដោយក្តីញញឹម។ ឃើញដូច្នេះ ព្រះ អនន្ទ ឈ្ងល់ណាស់ ក៏ថ្វាយបង្គំ ទូលសួរ សុំអោយព្រះអង្គ ពន្យល់ អំពីហេតុផល។ ព្រះអង្គ មានពុទ្ធដីការ ទស្សន៍ទាយថា តទៅ អនាគត កោះគោកធ្លកនេះ នឹងកកើតក្លាយ ជានគរមួយ ខ្លាំងក្លា មានទឹកដីធំទូលំទូលាយ, ប្រជាជន រស់នៅ ដោយសុខ សប្បាយក្សេមក្សាន្ត ថ្កុំថ្កើងរុងរឿង។ សត្វក្រកួត ដែលមានចិត្ត ល្អបរិសុទ្ធ លុះទៅដោយ ធម្មទេសនា របស់ព្រះពុទ្ធ ក្រោយដែល បានចាកលោកនេះទៅ នឹងបានកើតជា ព្រះរាជបុត្រ ស្ដេច នគរឥន្ទ្រាន្ត ហើយ នឹងយាងមកសោយរាជសម្ផត្តិ នៅនគរ គោកធ្លក។ ពេលនោះ ស្ដេចភជង្គនាគ នឹងចេញមករៀបចំ ទឹកដី ថ្វាយព្រះអង្គ។ ព្រះអង្គនឹងដាក់ឈ្មោះនគរគោកធ្លក ជា ‹កម្ពុជាធិបតី› ដែលនគរដទៃទៀត ដាក់ឈ្មោះហៅថា ‹ស្រុក ខ្មែរ›។ ឯព្រះឥន្ទ្រាធិរាជវិញ ក៏នឹងបញ្ជាអោយព្រះវិស្សុកម្ម ចុះ មកកសាង ប្រាង្គប្រាសាទធំល្អ្ហ ជាច្រើនទៀតដែរ តែ ប្រជា ជន នៅក្នុងប្រទេសកម្ពុជា គ្មានចិត្តស្នេះត្រង់ ប្រកាន់គោរព ពាក្យសំដី របស់ខ្លួន។ សំដីនិយាយចេញ មានន័យផ្សេង មិន ដូចចិត្តគំនិត ដែលយល់នោះទេ។ គឺ អណ្ដាត ព្រែកបែកជាពីរ ដូចសត្វក្រកួត ជីការបស់ខ្លួន។ »

តែខ្មែរ ក៏មានទំនាយ ព្យាករថា នៅពេលស្រុកខ្មែរ ជួបប្រទះ នឹង មហន្តរាយ, ពេលនោះ នឹងមាន ព្រះបាទធម្មិក (ស្ដេច

ប្រកបដោយធម៌) ទ្រង់ នឹងយាងចុះពី ឋានសួគ៌ មកជួយសង្គ្រោះប្រជាជនខ្មែរ ពីទុក្ខវេទនាគ្រប់បែបយ៉ាង។ មួយវិញទៀត នៅក្នុង ទស្សនៈ « បុណ្យ និង បាប » បើគេយកវាមកពិនិត្យ គឺ អ្នកប្រព្រឹត្តអំពើអ្វីមួយ ក្នុងបច្ចុប្បន្នកាល សំរាប់ ទទួលអំណោយផល ទៅអនាគតកាល ឬក៏ ក្នុងជាតិ ដែលកំពុងប្រព្រឹត្តិអំពើ, ឬក៏ ទៅជាតិក្រោយ ព្រោះ បាប រមែងឲផលអាក្រក់, បុណ្យ រមែងឲផលល្អ។ អំណោយផល ដែលកើតចេញមកពីអំពើ របស់អ្នកធ្វើ វាតែងដេញតាម អ្នកធ្វើ រៀងរហូត។ នៅពេល ដែលអំណោយផល វាចេញជា ផលាទុំល្អ, បើដេញតាមមិនទាន់ ក្នុងជាតិបច្ចុប្បន្ន ក៏វានៅតែដេញតាម ទៅជាតិក្រោយដែរ ដើម្បី ផ្តល់ជា លទ្ធផល តាមអំពើ «ល្អ ឬ អាក្រក់» របស់ខ្លួន។ ដូច្នេះ ទស្សនៈ នេះ ក៏មាន ចក្ខុវិស័យ ជា អបរកាលវិជ្ជា នោះដែរ។

នៅមស្ចមប្រទេស ពីបុព្វេ ក៏គេឃើញមាន ទំនាយជាច្រើនដែរ មាននៅក្នុងរឿងព្រះអាទិទេព, ព្យាករណ៍ នៃហោរ និង ទិព្វនេត្រ[1] របស់លោក Saint Augustin អំពី « បូរីរបស់អាទិទេព[2] » ដែល ជាការនិពន្ធមួយ ស្តីអំពី ប្រវត្តិ នៃមនុស្សជាតិ។ បន្ទាប់មក នៅសតវត្សទី១៧, មានអក្សរសិល្ប៍ ជាច្រើន នៃពួកអ្នកនិពន្ធ មានកំនិតហួសវិស័យ នាំគ្នាសរសេរ អំពី សង្គមឧត្តមចិត្ត ដែលនឹងកើតមាន នៅក្នុងអនាគតកាល នៃមនុស្សជា

[1] Vision surnaturelle.
[2] Saint Augustin : Cité des dieux.

តិ។ មកដល់ សតវត្ស ទី១៨, ទី១៩ គេឃើញ ចាប់ផ្តើមមាន សេចក្តីព្រោងដំបូង នៃ ព្យាករណ៍ យល់ដឹង[3] អំពីអនាគត ដែលវាខុសគ្នានឹង ទំនាយ ជា វិជ្ជា គ្មានយល់ដឹង[4] ទោះបីមាន ក្បួនតារាសាស្ត្រ ជាមូលដ្ឋានក៏ដោយ។ ភាពខុសគ្នា វាស្ថិតនៅលើមួយ ត្រដរយក លក្ខណៈវិនិច្ឆ័យ (critères) នៃវិទ្យាសាស្ត្រ ដើម្បីតាមលចូល ទៅអនាគតកាល រីឯ មួយទៀត យក ទិព្វនេត្រ ដូចក្នុង ពុទ្ធទំនាយ និង ចារីត របស់លោក Saint Augustin ដើម្បីព្យាករ អំពី អនាគតកាល។ ហើយ ទ្រឹស្តី អំពី អនាគត ដែលល្បីល្បាញបំផុត នៅមស្ចឹមប្រទេស គេអោយឈ្មោះហៅថា « ទស្សនវិជ្ជា នៃប្រវត្តិសាស្ត្រ » ដែលពួកអ្នកនិពន្ធល្បីៗ គេមានអំនួតថា គេអាចបង្កើតច្បាប់ ឬ ច្បាប់ក្រឹះ ស្តីអំពី ការវិវត្ត នៃសង្គមដែលវាបែងចែក ជាដំណាក់កាលផ្សេងៗគ្នា។ អ្នកនិពន្ធទាំងនោះ គឺលោក Auguste Comte, Claude-Henri de Saint Simon, Karl Marx, Herbert Spencer បាននាំគ្នា រចិត (élaborer) ច្បាប់ក្រឹះ ទាំងឡាយនោះ ជា ប្រព័ន្ធមួយ ដោយយល់ឃើញថា អនាគត ជា លទ្ធផល នៃអភិក្រម ចាំបាច់ជួនកាល វាជាមូលហេតុ នាំបង្កើតនូវព្រឹត្តិការណ៍ នៃអនាគត។ គំនិតកម្ម (pensée) លាយនឹងការសង្កេតដ៏ចំណាន របស់អ្នកទាំងនោះ ជាពិសេស អំពី ប្រធានបទ ចូលទៅក្នុងសម័យ វិទ្យាសាស្ត្រ និង ឧស្សាហកម្ម ជាមួយនឹង ការមើលឃើញជាមុន ពាក់

[3] Prévision raisonnée.
[4] Connaissance non raisonnée.

ព័ន្ធនឹង ដំណាក់កាល ចុងក្រោយ នៃមនុស្សលោក ឈមទៅរក អនាគត រាបង្ហាញ នូវការពិត គួរអោយចាប់អារម្មណ៍ ព្រោះវា មិនសុទ្ធតែជាកំនិតរវើរាយ ទាំងអស់នោះឡើយ ដូចលោក Herbert Spencer នៅសតវត្សទី១៩ គាត់បានសរសេរអំពី សង្គម នៃការកំសាន្ត និង សកម្មភាព រឫធម៌ ទៅអនាគត ហើយ ការស្រមៃ របស់គាត់ វាកើតមានល្អាក់ល្អមមែន នៅក្នុង សង្គមបច្ចុប្បន្ន។ ការមើលឃើញ ត្រូវបែបនេះ លោក Bernard Cazes, អ្នកនិពន្ធជីវប្រវត្តិ, គាត់ ហៅថា « សុន្ទរកថា ព្យាករណ៍ ដែលមានបំណង ទុកជា វិទ្យាសាស្ត្រ[5] »។ គេអាចសួរជាសំនួរថា ចុះបើការទស្សន៍ទាយ វាត្រូវពិតដូច្នេះដែរ តើទុកវាជាអ្វី ? ជា ចៃដន្យ ? ជជីកសួរបែបនេះ វាជាចំណុច នៃទំនាស់ ជាទម្រង់ រវាង វិទ្យាសាស្ត្រ នឹង វិជ្ជាមន្តអាគម ឬ រហស្សវិទ្យាសាស្ត្រ[6] នោះ ឯង។ តែ គោលដៅ របស់វាវិញ វាមាន បំណងប្រាថ្នាដូចគ្នា គឺ ស្វែងរកអនាគតដ៏ល្អមួយ ដែលមនុស្សលោក ប្រាថ្នាចង់បាន។ តែ មនុស្សលោក មិនរស់នៅជាមួយនឹង បំណងប្រាថ្នានោះទេ គឺវា ផ្ចិតជាប់នៅក្នុងបេះដូងនិងជ្រាបទៅក្នុងខួរក្បាលមនុស្ស តាំងពីយូរអង្វែងមកហើយដែលមិនអាចបោះបង់ និង រំលើង វាបានឡើយ ដរាបណា ការចង់ដឹង អំពីអនាគត របស់មនុស្ស វាជា ចលករ នៃបំណងប្រាថ្នា នៃអនាគតដ៏ប្រសើរមួយ ពុំនោះ សោធ វាគ្រាន់តែការស្រមៃហួសវិស័យ តែប៉ុណ្ណោះ។

[5] Discours prophétique à prétention scientifique.
[6] Science occulte.